# របាយការណ៍បូកសរុបការងារ ៦ ខែ

| | |
|---|---|
| របាយការណ៍សំរាប់ខែ : | កក្កដា- ធ្នូ ឆ្នាំ 2014 |
| ឈ្មោះគម្រោង: | សហគ្រិនវ័យក្មេង |
| ផ្នែក: | បង្កើនប្រាក់ចំណូល |
| អ្នករៀបចំរបាយការណ៍: | លី ពីសី |
| កាលបរិច្ឆេទរៀបរៀងរបាយការណ៍: | 31 ធ្នូ ឆ្នាំ 2014 |
| ចំនួនអ្នកទទួលផលដោយផ្ទាល់ពីគម្រោងក្នុងរយៈពេលនេះ( ប្រុស/ស្រី) | 137 នាក់ ( ចេក 70 យុវជន + ព្រៃផ្គាំរ 67 យុវជន) |
| ចំនួនអ្នកទទួលផលដោយប្រយោលពីគម្រោងក្នុងរយៈពេលនេះ | 2740 នាក់ (137 គ្រួសារ x 5 x 4 សមាជិក) |
| កំណែរបាយការណ៍ | ពង្រាង 1 |

## 1.0 ការណែនាំពីគម្រោង

ក្រុមយុវជនភូមិ ព្រៃផ្គាំរបានបង្កើត **ក្រុមអាជីវកម្មខ្នាតតូច** ដែលមានសមាជិកចំនួន 25 នាក់ដោយមានអ្នកសម្របសម្រួលសហគមន៍ជួយសម្របសម្រួល។

អ្នកសម្របសម្រួលសហគមន៍បានបន្តវគ្គបណ្តុះបណ្តាល**អាជីវកម្មខ្នាតតូច និងការអភិវឌ្ឍន៍ សហគមន៍** ដល់យុវជនភូមិព្រៃផ្គាំរចំនួន 25 នាក់។

ការពង្រឹងសមត្ថភាពក្រុមម្តងបញ្ចូលទាំងពីរភូមិ (ព្រៃផ្គាំរ និងចេក) មានអ្នកចូលរួមសរុប 73នាក់ ធ្វើនៅភូមិចេក។

ក្រុមមកពីប្រទេសម៉ាឡេស៊ី និងអាមេរិច បានចុះភូមិចេក និងព្រៃផ្គាំរ ចំនួន 31នាក់ ។

ក្រុមអង្គការគ្រួសារខ្មែរបានចុះភូមិចេកមានចំនួន 7 នាក់។

អ្នកសម្របសម្រួលសហគមន៍បានចុះជួបពិភាក្សាជាមួយលោកមេឃុំចំនួន 06 លើក ហើយនឹងបានចុះជួបពិភាក្សាជាមួយលោក អភិបាលស្រុកចំនួន 01 លើក។

ការចុះសម្របសម្រួលក្នុងសហគមន៍បានធ្វើរួចរាល់ដោយអ្នកសម្របសម្រួលសហគមន៍ និងបានត្រួតពិនិត្យតាមដានរួចរាល់ផងដែរដោយនាយកប្រតិបត្តិ **អង្គការដៃគូនាំផ្លូវនៅកម្ពុជា** (PPC) ។

## 2.0 ផែនការ និងលទ្ធផលសំរេចបាន

| ផែនការ សកម្មភាព និងលទ្ធផល | កិច្ចការបានបំពេញ | មូលហេតុផ្សេងៗ |
|---|---|---|
| | **ភូមិចេក** | |
| បន្តសម្របសម្រួលអោយយុវជនបង្កើតអាជីវកម្មនៅមូលដ្ឋានរបស់គេ | បានធ្វើរួចរាល់ | |
| ក្រុមរៀនពីអាជីវកម្មខ្នាតតូច | មានយុវជនបានចូលរួម 35 នាក់ (ស្រី26 នាក់) រៀនរាល់ថ្ងៃសៅរ៍ | |
| បង្រៀន និងណែនាំដំណើរការក្រុមសន្សំប្រាក់ និងកម្ចី | មានយុវជន 24 នាក់ (ស្រី 19 នាក់) បានចូលរួមក្រុមសន្សំប្រាក់។ សន្សំ 10,000 រៀលក្នុង 01ខែ ក្នុង 01នាក់។ មកដល់ពេលនេះប្រាក់សន្សំសរុបមានចំនួន 14,012,400 រៀល។ | |
| ថ្នាក់ភាសាអង់គ្លេស | មាន 2 ក្រុមៈ<br>- ក្រុមយុវជនមានចំនួន 25 នាក់( ស្រី16)<br>- ក្រុមកុមារមានចំនួន 15 នាក់( ស្រី13)<br>រៀនរាល់ថ្ងៃច័ន្ទ ដល់ សុក្រ | |
| ថ្នាក់អក្ខរកម្ម | - ក្រុមយុវជនមានចំនួន 4 នាក់ស្រីទាំងអស់ រៀនរាល់ថ្ងៃច័ន្ទ ដល់ សុក្រ | |
| ក្រុមកីឡា និងសុខភាព | ក្នុងក្រុមមានកីឡា 3 ប្រភេទដូចជាៈ បាល់ទះ, ទាត់សី និងវាយសី។ លេងជារៀងរាល់ល្ងាច ហើយអ្នកលេងជាមធ្យមមានចំនួន 15 នាក់។ | |
| ក្រុមអាជីវកម្មខ្នាតតូច | ➢ ក្រុមកាត់ដេរបានទទួលប្រាក់ចំណូលសរុប<br>ចំនួន 850 ដុល្លារ។<br>➢ ជាងកាត់សក់ មានអតិថិជនចំនួន 70 នាក់ បានចំណូល 210,000 រៀល។<br>➢ ក្រុមចិញ្ចឹមមាន់បានជួសជុលទ្រុងជាថ្មី និង បន្តចិញ្ចឹម និងលក់បានចំនួន 28 ក្បាល បានចំណូល 433,700រៀល។ ក្នុងទ្រុងមានមេមាន់ 18ក្បាល បា 3ក្បាល និងកូន 100 ក្បាល។<br>➢ ក្រុមដាំដំណាំមានសមាជិក 5 កំពុងដំណើរ ការក្រុម។ | ក្រៅពីការងារកាត់សក់ ជាងកាត់សក់ គាត់មានការងារស្រែចំការ ធ្វើជាងឈើ និងចិញ្ចឹមសត្វស្របពេលជាមួយគ្នា។ |
| ការចូលជួបជាមួយអាជ្ញាធរមូលដ្ឋាន | 24លើកជាមួយមេភូមិ (4លើកក្នុង1ខែ) 6ដងជាមួយលោកមេឃុំ(1លើកក្នុង1ខែ) និងជាមួយលោកអភិបាលស្រុក1លើក។ | |

| ផែនការ សកម្មភាព និងលទ្ធផល | កិច្ចការបានបំពេញ | មូលហេតុផ្សេងៗ |
|---|---|---|
| សម្របសម្រួលអោយយុវជនចេះភ្ជាប់បណ្តាញអាជីវកម្មរវាងអ្នកខាងក្នុង និងខាងក្រៅភូមិ | បានធ្វើរួចរាល់ | |
| ក្រុមម៉ាឡេស៊ី និងអាមេរិចមកមើលគម្រោង **សហគ្រិនវ័យក្មេង**(YEs) | បានធ្វើរួចរាល់។ មានចំនួន 20 នាក់ (ស្រី10) បានស្នាក់នៅភូមិ 3 ថ្ងៃ 2 យប់។ ក្រុមបានអោយ **អណ្តូងលូ** ទៅ 4 **អណ្តូង**, ទ្រុងមាន់ និងទ្រុងជ្រូក ដល់គ្រួសារយុវជនភូមិចេក។ | |
| | **ភូមិព្រៃផ្តៅ** | |
| វគ្គបណ្តុះបណ្តាលស្តីពី **អាជីវកម្មខ្នាតតូច និងការអភិវឌ្ឍន៍សហគមន៍** | បានធ្វើរួចរាល់ | |
| ការបង្កើតក្រុម **អាជីវកម្មខ្នាតតូច** | មានយុវជន 25 នាក់ (ស្រី 20 នាក់) កំពុងដំណើរក្រុមដាំដំណាំ និងក្រុមចិញ្ចឹមមាន់ | |
| បង្រៀន និងណែនាំដំណើរការសមាគមសន្សំប្រាក់ និងកម្ចីភូមិព្រៃផ្តៅ | មានយុវជន 24នាក់ (ស្រី 17នាក់) បានចូលរួមក្រុមសន្សំប្រាក់។ សន្សំ 10,000រៀល ក្នុង 1ខែក្នុង 1នាក់។ មកដល់ពេលនេះសរុបប្រាក់ សន្សំ មានចំនួន 3,256,500 រៀល។ | |
| ក្រុមកីឡា និងសុខភាព | ក្នុងក្រុមមានកីឡា 2 ប្រភេទដូចជា៖ បាល់ទះ និង ទាត់សី លេងជារៀងរាល់ល្ងាច ហើយ អ្នកលេងជាមធ្យមមានចំនួន18 នាក់។ | |
| វគ្គបណ្តុះបណ្តាលស្តីពី **ការពង្រឹងសហគមន៍** | មិនទាន់បានធ្វើ | បន្ទាប់ពីច្រូតកាត់រួចរាល់ |
| សម្របសម្រួលអោយយុវជនបង្កើតអាជីវកម្មនៅមូលដ្ឋានរបស់គេ | កំពុងបន្ត | |
| ការចូលជួបជាមួយអាជ្ញាធរមូលដ្ឋាន | 24 ដងជាមួយមេភូមិ ( 4 ដងក្នុង1ខែ) 6 ដងជាមួយលោកមេឃុំ( 1 ដង ក្នុង 1ខែ) និងជាមួយលោកអភិបាលស្រុក1 ដង។ | |
| ក្រុមម៉ាឡេស៊ី និងអាមេរិចមកមើលគម្រោង **សហគ្រិនវ័យក្មេង**(YEs) | បានធ្វើរួចរាល់។ មានចំនួន 11 នាក់ (ស្រី7) បានស្នាក់នៅភូមិ 3 ថ្ងៃ 2 យប់។ ក្រុមបានអោយ **អណ្តូងលូ** ទៅ 1 **អណ្តូង**, ទ្រុងមាន់ និងទ្រុងជ្រូក ដល់គ្រួសារយុវជនភូមិចេក។ | |

## 3.0 ឧបសគ្គ និងដំណោះស្រាយ

បន្ទាប់ពីប្រមូលផលស្រូវហើយ យុវជនមួយចំនួនចង់ចំណាកស្រុកទៅប្រទេសថៃ។ ដូច្នេះហើយ អ្នកសម្របសម្រួលសហគមន៍ បានទៅដល់លំនៅស្ថានរបស់ពួកគេដើម្បីជំរុញ និង លើកទឹកចិត្តអោយគេគិតសារជាថ្មីដោយបានផ្តល់គំនិត និងបង្ហាញអំពីមធ្យោបាយដែលល្អ បំផុតក្នុងការធ្វើការនៅក្នុងភូមិដោយប្រើប្រាស់ធនធាន និងចំណេះដឹងរបស់ពួកគាត់ដែលមាន។

## 4.0 មេរៀនដែលរៀនបានសំខាន់ៗ

យុវជនដែលបានចូលរួមជាមួយគម្រោង **សហគ្រិនវ័យក្មេង**(YEs) ភាគច្រើនបានផ្លាស់ប្តូរដូចជា៖ មានការទំនាក់ទំនងល្អ មានជំនឿចិត្តលើខ្លួនឯងច្រើនជាងមុន,មានភាពក្លាហានបង្ហាញសមត្ថភាព និងអាចជួយខ្លួនឯង និងអ្នកភូមិបាន ពីព្រោះពួកគេបានចូលរួមវគ្គបណ្តុះបណ្តាល និងរៀនពីគម្រោង។

## 5.0 សហគមន៍

សហគមន៍នៃ PPC-YEs គឺយុវជន, គ្រួសាររបស់យុវជន, អ្នកភូមិ, អាជ្ញាធរមូលដ្ឋាន បុគ្គលិករបស់ PPC-YEs ហើយនឹងម្ចាស់ជំនួយ។

## 6.0 បញ្ហាយេនឌ័រ

PPC-YEs ផ្តែកលើសម្បភាពយេនឌ័រ ដែរ 72.26 ភាគរយ គឺជាស្រ្តី (ស្រី 99 នាក់/137 យុវជន) ។ អ្នកដឹកនាំក្រុមយុវជនសាមគ្គីគឺជាស្រ្តី។ អ្នកភូមិបានយល់ច្បាស់ថាស្រ្តី និងបុរសមានសិទ្ធិស្មើគ្នា ហើយសង្ឃឹមថាសមភាពនេះវានឹងបន្តរីកចំរើនល្អឡើង ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់។

## 7.0 បណ្តាញទំនាក់ទំនងជាមួយរដ្ឋាភិបាល

PPC-YEs នឹងបន្តព្យាយាមអោយអស់លទ្ធភាព ដើម្បីបង្កើតបណ្តាញជាមួយ NGOs ផ្សេងទៀត តាមដែលអាចធ្វើទៅបាន។

## 8.0 ការអភិវឌ្ឍន៍ធនធានមនុស្ស

បុគ្គលិក PPC-YEs បានចូលរួមប្រជុំប្រចាំខែនៅការិយាល័យ PPC ភ្នំពេញ ដើម្បីរាយការណ៍នូវអ្វីៗដែលបានធ្វើ ហើយនឹងរៀនពីបទពិសោធន៍ផ្សេងៗ របស់គម្រោង/កម្មវិធី ដទៃទៀតនៅក្នុង PPC។

អ្នកសម្របសម្រួលសហគមន៍បានជួបប្រជុំជាទៀងទាត់ជាមួយ នាយកប្រតិបត្តិនៅការិយាល័យគម្រោង PPC-YEs នៅខេត្តសៀមរាប មួយខែម្តង។

បុគ្គលិក PPC-YEs ថ្មីបានរៀនពីរបៀបធ្វើការជាអ្នកសម្របសម្រួលល្អពី អ្នកសម្របសម្រួលចាស់ និងនាយកប្រតិបត្តិ(PPC-ED)

បុគ្គលិក PPC-YEs បានចូលរួមវគ្គបណ្តុះបណ្តាលស្តីអំពី **ភាពជាអ្នកដឹកនាំបែបបំរើ**

PPC-YEs នឹងបញ្ជូនបុគ្គលិកទៅចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ ពេលដែលមានថវិកាគ្រប់គ្រាន់។

## 9.0 ការត្រួពិនិត្យ និងវាយតម្លៃសកម្មភាព

PPC-ED បានចុះទៅត្រួតពិនិត្យគម្រោងនៅសហគមន៍ដោយផ្ទាល់ និងបានតាមដានតាមទូរស័ព្ទ និងបានជួបយុវជន ហើយនឹងក្រុមដឹកនាំយុវជនផងដែរ។ អ្នកសម្របសម្រួលសហគមន៍បានសរសេររបាយការណ៍ចុះសួរសុខទុក្ខ និងរបាយការណ៍ប្រចាំខែទៅអោយនាយកប្រតិបត្តិដើម្បីរាយការណ៍នូវអ្វីដែលជាឧបសគ្គ និងដំណោះស្រាយដែលជួបប្រទះ។ នាយកប្រតិបត្តិបានអានរបាយការណ៍ ហើយអោយនូវអនុសាសន៍ផ្សេងៗ និងដំបូលន្មានល្អៗជាច្រើនដល់អ្នកសម្របសម្រួលសហគមន៍។

## 10.0 ផែនការអនុវត្តរយៈពេលបន្ទាប់

| សកម្មភាព | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា |
|---|---|---|---|---|---|---|
| ការប្រជុំប្រចាំខែរបស់បុគ្គលិក | x | x | x | x | x | x |
| ការចុះសហគមន៍របស់អ្នកគ្រប់គ្រង | x | x | x | x | x | x |
| របាយការណ៍បូកសរុប ៦ខែក្រោយ | | | | | | x |
| ក្រុមមកពីអាមេរិចចុះភូមិ | x | | | | | |
| ម្ចាស់ជំនួយវាយតម្លៃគម្រោង | x | | | | | |
| ការជួបជុំក្រុមសាមគ្គីនិងកសាងសមត្ថភាពក្រុម | x | | | | | |
| ការបោះជំរុំយុវជនឆ្នាំ 2015 ទៅខេត្តព្រះវិហារ | | | | x | | |
| **ភូមិចេក** | | | | | | |
| អ្នកសម្របសម្រួលចុះសមគមន៍ | x | x | x | x | x | x |
| ប្រជុំក្រុមយុវជនសាមគ្គី | x | x | x | x | x | x |
| ប្រជុំក្រុមអ្នកដឹកនាំយុវជនសាមគ្គី | x | x | x | x | x | x |
| ក្រុមរៀនពីអាជីវកម្មខ្នាតតូច | x | x | x | x | x | x |
| ថ្នាក់អក្ខរកម្ម | x | x | x | x | x | x |
| ថ្នាក់ភាសាអង់គ្លេស | x | x | x | x | x | x |
| ក្រុមសុខភាព និងកីឡា | x | x | x | x | x | x |
| ក្រុមសន្សំប្រាក់ និងកម្ចី | x | x | x | x | x | x |
| ក្រុមអាជីវកម្មខ្នាតតូច | x | x | x | x | x | x |
| វគ្គចិញ្ចឹមសត្វ | | x | | | | |
| **ភូមិព្រៃផ្គារ** | | | | | | |
| អ្នកសម្របសម្រួលចុះសមគមន៍ | x | x | x | x | x | x |
| ប្រជុំក្រុមយុវជនសាមគ្គី | x | x | x | x | x | x |
| ប្រជុំក្រុមអ្នកដឹកនាំយុវជនសាមគ្គី | x | x | x | x | x | x |
| ថ្នាក់ភាសាអង់គ្លេស | x | x | x | x | x | x |
| ថ្នាក់គណិតវិទ្យា | x | x | x | x | x | x |
| ក្រុមសន្សំប្រាក់ និងកម្ចី | x | x | x | x | x | x |
| ក្រុមសុខភាព និងកីឡា | x | x | x | x | x | x |
| វគ្គការលក់ និងការស្វែងរកទីផ្សារ | x | x | | | | |
| វគ្គការពង្រឹងសហគមន៍ | | | x | x | | |
| ក្រុមអាជីវកម្មខ្នាតតូច | x | x | x | x | x | x |

## 11.0 ផ្នែកហិរញ្ញវត្ថុ

- គម្រោងមានផ្នែករដ្ឋបាល ឬគណនេយ្យ នៅការិយាល័យ PPC ភ្នំពេញ
- PPC-YEsមានថវិកា 5,279USD ហើយចំណាយអស់ 4,343.87 USD ក្នុងរយៈពេល៦ខែនេះ។

## 12.0 សកម្មភាពផ្សេងៗ





សកម្មភាពបោះជំរុំយុវជនឆ្នាំ 2014





វគ្គបណ្តុះបណ្តាល ភាពជាអ្នកដឹកនាំ





សកម្មភាពបង្កើនប្រាក់ចំណូលរបស់យុវជន



